បទបញ្ជាពេទ្យសំរាប់ការព្យាបាលទ្រទ្រង់ជីវិតនៃរដ្ឋម៉ាស្សាជូសេត (Massachusetts Medical Orders for Life-Sustaining Treatment, MOLST) គឺជាសេចក្តីណែនាំដែលបានសរសេរឡើង អំពីការព្យាបាលរោគខ្លះ ដែលអាចនឹងបានប្រើ ដើម្បីព្យាយាមរក្សាមនុស្សឲ្យរស់រាន។ បទបញ្ជា MOLST អាចនឹងបានសរសេរ សំរាប់អ្នកជំងឺ ដែលជីវិតរបស់គេអាចនឹងផុតនៅឆ្នាំក្រោយ ដោយព្រោះជំងឺជំលឿនធ្ងន់ធ្ងរ។ បទបញ្ជាត្រូវបានសរសេរឡើង ដោយអ្នកពិនិត្យព្យាបាល (វេជ្ជបណ្ឌិត ពេទ្យអនុវេជ្ជបណ្ឌិត ឬអនុការីវេជ្ជបណ្ឌិត) នៅលើក្រដាសបំពេញ ពណ៌ផ្កាឈូកភ្លឺ ទាំងបានចុះហត្ថលេខាដោយស្ម័គ្រចិត្ត ដោយអ្នកជំងឺ *និង* វេជ្ជបណ្ឌិត ពេទ្យអនុវេជ្ជ បណ្ឌិត ឬអនុការីវេជ្ជបណ្ឌិត។ ក្រដាសបំពេញ MOLST ប្រាប់អ្នកវិជ្ជាជីវៈ ថែសុខភាពផ្សេងៗទៀត អំពីអ្វី គួរតែបានធ្វើ ឬអ្វីមិនគួរបានធ្វើ ដើម្បីព្យាយាមរក្សាមនុស្សឲ្យរស់ ដោយយោងទៅលើការព្យាបាលដែល អ្នកជំងឺចង់បាន ឬអ្វីដែលមិនចង់បាន។

នេះគឺជាការបកប្រែជាភាសាខ្មែរ នៃក្រដាសបំពេញ MOLST រដ្ឋម៉ាស្សាជូសេត្ត។ ក្រដាសបំពេញដែលបានបកប្រែ ត្រូវបានប្រើសំរាប់ជួយអ្នកជំងឺ និងសមាជិកគ្រួសាររបស់គាត់ ឲ្យយល់ដឹងនូវសេចក្តីនៃក្រដាសបំពេញ MOLST នៅពេលធ្វើការសំរេចចិត្ត អំពីការព្យាបាលដែលមានបញ្ចូលនៅក្នុងវា។ <u>ក្រដាសបំពេញដែលបានបកប្រែ មិនគួរបានចុះហត្ថលេខាឡើយ</u>។ ក្រដាសបំពេញ MOLST ដែលត្រូវចុះហត្ថលេខា ត្រូវតែជាភាសាអង់គ្លេស ប្រយោជន៍ឲ្យបុគ្គលិកថែទាំសុខភាពអាចយល់ដឹង និងអាចធ្វើតាមបទបញ្ជាបាន។

Frequently Asked Questions about MOLST

Sample MOLST form in Khmer